# NSW FIRE BRIGADES

## និរភ័យអំពីថ្នាំជាតិគីមីប្រើប្រាស់នៅក្នុងផ្ទះ

Fact Sheet 23- Community Risk Management.  Revised 1/11/2005

### ហេតុការណ៍ពិត

នៅឆ្នាំ២០០១ មានករណីគ្រោះថ្នាក់ពុលចំនួន៨៤៥៨ ដែលតម្រូវឲ្យអ្នកជម្ងឺចូលដេកក្នុងមន្ទីរពេទ្យ ហើយអ្នករងគ្រោះភាគច្រើនៗជាកុមារ។  មូលនិធិការពារគ្រោះថ្នាក់ដល់កុមារអូស្ត្រាលី (The Child Accident Prevention Foundation of Australia) បានរាយការណ៍ថា រាល់អាទិត្យ មានកុមារប្រហែលជា៥០នាក់ បានត្រូវដឹកទៅមន្ទីរពេទ្យដោយសារពុល។
ជាតិគីមីមិនត្រឹមតែបានប្រើនៅក្នុងផ្នែកផលិតកម្មនិងឧស្សាហកម្មធំៗទេ តែវាជាផ្នែកមួយនៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សយើងដែរ។  ផលិតផលទាំងឡាយដែលយើងប្រើសំរាប់សំអាតចង្ក្រាននិងបន្ទប់ទឹក បោកសម្លៀកបំពាក់និងចានក្បាន សម្លាប់សត្វល្អិតនិងជីជាតិដំណាំ ទាំងអស់នេះជាជាតិគីមី ក៏ដូចជាថ្នាំលាប ថ្នាំដុសខាត់ឡាននិងតុទូ ថ្នាំខ្លីរីនសំរាប់អាងហែលទឹក ប្រេងសាំង ប្រេងម៉ាស៊ីន ប្រេងហ្វ្រាំងឡាននិងប្រេងLPG។
ម មានផលិតផលប្រើប្រាស់នៅក្នុងផ្ទះជាច្រើនទៀតដែលយើងមិនចាត់ទុកជាជាតិគីមី ដូចជា សាប៊ូលាងខ្លួន ថ្នាំកក់សក់ ថ្នាំលាបបំបាត់ក្លិន និងទឹកអប់ ថ្នាំពេទ្យ ថ្នាំក្អកនិងថ្នាំមានបញ្ហា:
□ ពីពេទ្យ ថ្នាំវីតាមីន ថ្នាំបុសឈើ  និងផលិតផលសំរាប់លាងសំអាតដែលមិនប្រើជាតិគីមី។
គឺជាការសំខាន់ដែលគេត្រូវទុកដាក់ជាតិគីមីទាំងនោះឲ្យបានស្រួលបួល ហើយប្រើទៅតាមការណែនាំឲ្យបានត្រឹមត្រូវ។

**ជាតិគីមីអាចធ្វើឲ្យពុល អាចឆេះ ឬអាចមានប្រតិកម្មយ៉ាងខ្លាំងនៅពេលដែលលាយជាមួយគ្នា។**

### ការណែនាំអំពីការទុកដាក់និងប្រើជាតិគីមីដោយគ្មានគ្រោះថ្នាក់

សូមរក្សាផ្ទះរបស់អ្នកឲ្យចាកផុតពីគ្រោះថ្នាក់! ក្រុមពន្លត់ភ្លើងរដ្ឋញូសៅវែលផ្តល់បញ្ជីឆែកឆេរការពារគ្រោះថ្នាក់ដ៏ងាយនេះមួយ៖

- ✓ ត្រូវ**អានផ្លាក**មុននឹងទិញជាតិគីមីណាមួយ។  ត្រូវយល់អំពីរបៀបប្រើឲ្យប្រាកដ និងគ្រោះថ្នាក់នានាពីជាតិគីមីនោះ
- ✓ ត្រូវ**រើស**របស់ដែលមានគ្រោះថ្នាក់តិចជាងគេ ហើយដែលប្រើការឲ្យបានប្រយោជន៍ ជាពិសេសនៅពេលដែលមានក្មេងនៅជាមួយ
- ✓ ត្រូវដាក់ជាតិគីមីនៅក្នុង**ទូចាក់សោ** ឲ្យនៅឆ្ងាយពីដៃក្មេង។  **ទុក**ជាតិគីមីដែលគ្រោះថ្នាក់ជាងគេនៅលើធ្នើទូដែលទាបជាងគេ។  **ចូរចាំថា** កុមារច្រើនតែងឿងឆ្ងល់ ចូលចិត្តប្រឌិត ហើយពូកែវារឡើងផង
- ✓ ត្រូវ**ធ្វើតាម**សេចក្តីណែនាំរបស់ផលិតករ។  ត្រូវកាន់ដោយប្រយ័ត្នប្រយែង។  ត្រូវប្រើគ្រឿងប្រដាប់ការពារដែលគេណែនាំ៖ ស្រោមដៃ គ្រឿងពាក់ភ្នែកសំរាប់ការពារ ។ល។ ត្រូវឲ្យប្រាកដថាមាន**ខ្យល់បក់**ឲ្យគ្រប់គ្រាន់
- ✓ ត្រូវ**លាង**កំរាលឲ្យស្អាតក្រោយពីប្រើរួច និងមុននឹងចោលក្នុងធុងសម្រាម
- ✓ **បិទ**ជាតិគីមីនៅក្នុងដបឲ្យជិត។  ត្រូវដាក់ផ្លាកគ្រប់ដប**ឲ្យច្បាស់ៗ**
- ✓ **ចូរចាំថា** ថ្នាំខ្លះមានសណ្ឋានដូចជា**ម្ហូបទទួលទាន ឬទឹកសំរាប់ផឹក**។  ត្រូវ**ចាក់សោ**ទុកឲ្យឆ្ងាយពីក្មេង
- × **មិនត្រូវលាយ**បញ្ចូលជាតិគីមីឡើយ
- × **មិនត្រូវរៀបចំ**ជាតិគីមីច្រើនលើសពីសេចក្តីត្រូវការ
- × **មិនត្រូវ**ប្រើជាតិគីមីសំរាប់ការងារដែលមិនត្រូវប្រើជាតិនោះ
- × **មិនត្រូវ**ចាក់ជាតិគីមីទៅក្នុងលូទឹក បង្គន់ ឬតាមទទឹក។

### អ្វីដែលត្រូវធ្វើ

តើអ្នកបាន**ត្រួតពិនិត្យ**កន្លែងទុកដាក់ជាតិគីមី ព្រមទាំងគំរបដបក្នុងពេលថ្មីៗនេះទេ?

- តើអ្នកបាន**ទាក់ទង**សាលាក្រុងក្នុងដំបន់ដើម្បី**បោះចោល**ជាតិគីមីចាស់ៗឬសេសសល់ឬទេ?
  សូមមើល: http://www.resource.nsw.gov.au/cleanout/chemical_collection.htm
- សូម**ធ្វើតាម**ការណែនាំអំពីការព្យាបាលបន្ទាន់។  បើមាន**រលាក**ស្បែកឬភ្នែក ឬ**លេប**ឬ**ផឹក**ជាតិគីមី ឬ**ហិត**ចំហាយ សូមទៅរកការព្យាបាលជាបន្ទាន់
- **សូមចាំលេខទូរស័ព្ទ**ផ្តល់ពត៌មានអំពីការពុល ១៣១ ១២៦
  ចំពោះពត៌មានបន្ថែម សូមទាក់ទងជាមួយស្ថានីយក្រុមពន្លត់ភ្លើងក្នុងដំបន់អ្នក ឬ រកមើល: www.fire.nsw.gov.au

## ពេលអាសន្ន សូមទូរស័ព្ទលេខ 000